ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# សូមគោរពជូន
# លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

**តាមរយៈ៖** -ឯកឧត្តមឧត្តមសេនីយ៍ឯក អគ្គលេខាធិការរងទទួលបន្ទុក
-លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ

**កម្មវត្ថុ** ៖របាយការណ៍ ស្តីពីការរៀបចំ ទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស ២០ សីហា ឆ្នាំ២០២៥។

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មេត្តាជ្រាបថា នៅថ្ងៃពុធ ១១រោច ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩ ត្រូវនឹងថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៥ វេលាម៉ោងពីរ នឹងសាមសិបនាទីរសៀល អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានរៀបចំទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស ២០ សីហា ឆ្នាំ២០២៥ លើកទី៩ ក្រោមប្រធានបទ «សុខដុមនីយកម្មសាសនានៅកម្ពុជា ជាសក្តានុពលក្នុងការប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់នាសម័យបច្ចេកវិទ្យា» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលោកជំទាវ **កែ សួនសុភី ស សុខា** តំណាងដ៏ខ្ពង់ខ្ពស់បំផុត សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី** នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិជ្រោយចង្វារ (OCIC)។

## I. សមាសភាពយាងនិមន្ត និងអញ្ជើញចូលរួម

-សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត **បួរ គ្រី** សម្តេចព្រះមហាសង្ឃរាជ គណៈធម្មយុត្តិកនិកាយ និងជាប្រធានគណៈសង្ឃនាយកគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះពុទ្ធជ័យមុន្នី **ឃឹម សន** សម្តេចព្រះសង្ឃនាយករងទី៣ គណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា និងជាមេគណរាជធានីភ្នំពេញ

-ឯកឧត្តម លោកជំទាវ សមាជិករាជរដ្ឋាភិបាល ព្រឹទ្ធសភា រដ្ឋសភា

-ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គាធិការ អគ្គាធិការរង អគ្គនាយក អគ្គនាយករង និងថ្នាក់ដឹកនាំ នៃបណ្តាក្រសួង ស្ថាប័ន សមាជិក គ.ជ.ប.ជ ថ្នាក់ក្រោមជាតិ ឯកឧត្តម លោកជំទាវ ជាតំណាងអង្គទូត និងស្ថានតំណាង នៃបណ្តាប្រទេសជាមិត្តប្រចាំនៅព្រះរាជាណាចក្រកម្ពុជា តំណាងព្រះពុទ្ធសាសនា ឥស្លាមសាសនា គ្រីស្ទសាសនា តំណាងយុវជន យុវនារី និងតំណាងអង្គការដៃគូ ជាតិ-អន្តរជាតិ សរុបប្រមាណ ២.០០០អង្គ/រូប។

## II. មតិស្វាគមន៍ និងរបាយការណ៍សង្ខេប

ជាកិច្ចចាប់ផ្ដើម លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានថ្លែងនូវ គារវកិច្ច ថ្វាយបង្គំ ចំពោះព្រះវត្តមានសម្ដេចសង្ឃ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងថ្លែងអំណរគុណ ចំពោះវត្តមានដ៏ឧត្ដុង្គឧត្ដម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ**... 

**ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលោកជំទាវ **កែ សួនសុភី ស សុខា** តំណាងដ៏ខ្ពង់ខ្ពស់ សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី** ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន អភិបាល អភិបាលរង រាជធានី-ខេត្ត លោក-លោកស្រី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ ដែលបានឆ្លៀតឱកាសដ៏មមាញឹក អញ្ជើញចូលរួមក្នុងកម្មវិធីទិវាជាតិអន្តរសាសនា ២០ សីហា ឆ្នាំ២០២៥ ក្រោមប្រធានបទ «សុខដុមនីយកម្មសាសនានៅកម្ពុជា ជាសក្ដានុពលក្នុងការប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់នាសម័យបច្ចេកវិទ្យា» នាពេលនេះ។

លោកជំទាវ បានសម្ដែងនូវការគោរពដឹងគុណចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបាន និងកំពុងតែបន្តយកចិត្តទុកដាក់ចំពោះសុវត្ថិភាពប្រជាពលរដ្ឋ ដែលកំពុងរងនូវហានិភ័យពីគ្រោះមហន្តរាយ ដែលបង្កឡើងដោយកត្តាធម្មជាតិ និងកត្តាមនុស្ស ជាពិសេសអំពើជួញដូរ និងកេងប្រវ័ញ្ចលើមនុស្សគ្រប់ទម្រង់ ដែលក្នុងឱកាសនេះ គឺជាយុទ្ធនាការដ៏ធំមួយ ដែលត្រូវបានរៀបចំឡើង ដើម្បីផ្សព្វផ្សាយ បំផុសស្មារតី ដល់ថ្នាក់ដឹកនាំ និងប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ឱ្យរួមគ្នាបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ ដែលបាននិងកំពុងធ្វើឱ្យមនុស្សរងទុក្ខ បាត់បង់ភាពជាមនុស្ស និងទទួលរងនូវការកេងប្រវ័ញ្ចពីឧក្រិដ្ឋជនយ៉ាងសាហាវឃោរឃៅ នៅក្នុងប្រទេស ក្នុងតំបន់ និងក្នុងពិភពលោក។ វិបត្តិសង្គម ដែលបង្កឡើងដោយជម្លោះប្រដាប់អាវុធ និងសង្គ្រាមបង្ហូរឈាម ក៏ត្រូវបានកើតឡើងជាបន្តបន្ទាប់ និងរាលដាលពីតំបន់មួយទៅតំបន់មួយ ដែលធ្វើឱ្យប្រទេសដែលធ្លាប់តែមានទំនាក់ទំនងល្អជាមួយគ្នា បែរជាប្រឈមមុខដាក់គ្នា លែងមានកិច្ចសហការ និងយោគយល់គ្នា ជាក់ស្ដែង កម្ពុជាកំពុងទទួលរងគ្រោះយ៉ាងធ្ងន់ធ្ងរ ដោយមិននឹកស្មានដល់ ថាសូម្បីតែប្រទេសភូមិផងរបងជាមួយ ក៏មានតែការប្រកួតប្រជែង រហូតដល់មានការរំលោភឈ្លានពានគ្នា វាយប្រហារគ្នាដោយឥតកោតក្រែង បំផ្លាញអាយុជីវិតមនុស្ស សម្បត្តិវប្បធម៌ ដោយឥតស្ដាយស្រណោះ តាមរយៈការប្រើអាវុធធុនធ្ងន់ គ្រាប់ផ្លោង ទម្លាក់គ្រាប់បែក ប្រើផ្សែងពុលបំផ្លាញជីវិតប្រជាជនស្លូតត្រង់ដោយឥតរើសមុខ បង្កើតជាមហន្តរាយដ៏ធំធេង និងមានផលប៉ះពាល់យូរអង្វែងដល់ការរស់នៅរបស់មនុស្ស សត្វ និងធម្មជាតិ។ ទង្វើទាំងនេះ អាចកើតមានឡើងបាន អាស្រ័យដោយមនុស្សខ្វះសីលធម៌ មនុស្សធម៌ អាត្មានិយម ឈ្នានីស ព្យាបាទ មិនឱ្យអ្នកដទៃបានសុខ។ ក្នុងគ្រាដ៏លំបាកសម្រាប់ការរស់នៅរបស់មនុស្ស ដែលបាននិងកំពុងរងវិបត្តិ និងពោរពេញដោយការភ័យខ្លាច បានបង្កលក្ខណៈ ឱ្យឧក្រិដ្ឋជន ឆក់ឱកាសធ្វើសកម្មភាពបោកបញ្ឆោត អូសទាញមនុស្សឱ្យធ្លាក់ចូលក្នុងភាពរងគ្រោះដោយអំពើជួញដូរ និងធ្វើការកេងប្រវ័ញ្ចតាមគ្រប់រូបភាពបន្ថែមទៀត។

ក្នុងការងារបង្ការទប់ស្កាត់ វិស័យសាសនា បានដើរតួយ៉ាងសំខាន់ ក្នុងការផ្សព្វផ្សាយអប់រំ ពង្រឹង សតិ ស្មារតីដល់មនុស្សគ្រប់វ័យ ឱ្យរឹងប៉ឹង តស៊ូ ព្យាយាម ជម្នះឧបសគ្គ និងចេះប្រុងប្រយ័ត្នស្មារតី មិនធ្លាក់ចូលទៅក្នុងឧបាយកល នៃជនល្មើស ដែលព្យាយាម អូសទាញមនុស្សទៅក្នុងភាពរងគ្រោះ ងាយស្រួលក្នុងការកេងប្រវ័ញ្ចគ្រប់រូបភាព។ តាមរយៈការអប់រំបែបសាសនា ធ្វើឱ្យមនុស្សកាត់បន្ថយនូវភាពភ្លើតភ្លើន លោភលន់ ចេះយល់អធ្យាស្រ័យ ចេះគោរព និងឱ្យតម្លៃ ដល់ជីវិតមនុស្ស ចេះចែករំលែក ផ្ដល់ក្ដីមេត្តា មិនរំលោភបំពានគ្នា និងជួយគ្នាទៅវិញទៅមក ដែលនេះគឺ

ជាមូលដ្ឋានគ្រឹះក្នុងការទប់ស្កាត់ និងលុបបំបាត់នូវទង្វើអសីលធម៌ ទាំងឡាយដែលជាការជួញដូរ កេងប្រវ័ញ្ច និងរំលោភបំពានលើមនុស្សផងគ្នា ហើយផ្ដល់នូវសេចក្ដីសុខឱ្យគ្នាទៅវិញទៅមក។ ការបង្ការទប់ស្កាត់ ត្រូវបានធ្វើឡើងតាមវិធីសាស្ត្រជាច្រើន រួមទាំងការអប់រំផ្ទាល់ ការផ្សព្វផ្សាយអប់រំតាមវេទិកាសាធារណៈ ក្នុងគោលនយោបាយភូមិឃុំ-សង្កាត់ មានសុវត្ថិភាព សិក្ខាសាលា វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈ និងឯកជន និងយុទ្ធនាការថ្នាក់ជាតិ ដែលបន្តទៅថ្នាក់ក្រោមជាតិ រួមមាន ទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស និងទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ជាដើម។

នៅក្នុងឆមាសទី១ ឆ្នាំ២០២៥ នេះ តាមរបាយការណ៍របស់ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ បានចូលរួមដាក់វិធានការទប់ស្កាត់សកម្មភាព ដែលសង្ស័យថាពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ដោយពិនិត្យ សង្កេតលើតំរុយដែលគួរសង្ស័យ ចំពោះជនមួយចំនួនដែលឆ្លងកាត់តាមច្រកទ្វារអន្តរជាតិ ដើម្បីកំណត់សញ្ញាណនៃជនសង្ស័យជាមេខ្យល់ ឬជាជនល្មើសជួញដូរមនុស្ស ឬជាជនងាយរងគ្រោះ ដែលចាំបាច់ត្រូវធ្វើការទប់ស្កាត់ជាបន្ទាន់។ ក្នុងនេះ មន្ត្រីច្រកទ្វារអន្តរជាតិ បានរកឃើញនិងឃាត់ខ្លួនអ្នកដំណើរជនជាតិខ្មែរ ដើម្បីបង្ការទប់ស្កាត់ការចាញ់បោកការអូសទាញរបស់មេខ្យល់ជួញដូរមនុស្សដើម្បីកេងប្រវ័ញ្ចនៅក្រៅប្រទេស បានជាង ១០០ករណី និងបានធ្វើការបណ្តេញចេញជនបរទេសមួយចំនួន ដែលត្រូវបានរកឃើញថាបានចូលមកស្នាក់នៅ និងធ្វើសកម្មភាពខុសច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ចំនួន៤៨១លើក មានមនុស្ស ៥.៨៩៩នាក់ មាន៤៥សញ្ជាតិ។

ទន្ទឹមនឹងនោះ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណៈកម្មការចំពោះកិច្ចប្រយុទ្ធប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (Online Scams) បានដាក់ចេញវិធានការដ៏មុតស្រួច ដោយបានជំរុញឱ្យកម្លាំងសមត្ថកិច្ចទាំងថ្នាក់ជាតិ និងរាជធានី-ខេត្តទូទាំងប្រទេសចុះ បង្ក្រាបព្រមៗគ្នា រាល់ទីតាំងដែលសង្ស័យថាមានបង្កប់សកម្មភាពឆបោកតាមប្រព័ន្ធអនឡាញ យ៉ាងសកម្ម ជាបន្តបន្ទាប់ដូចភ្លៀងរលឹម ដើម្បីបោសសម្អាតបទល្មើសឆបោកតាមអនឡាញ យ៉ាងមានប្រសិទ្ធភាព ដើម្បីបង្កើតលំហរសុវត្ថិភាពកាន់តែទូលំទូលាយ សម្រាប់ការរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា និងជនបរទេសដែលស្នាក់នៅ ធ្វើការប្រកបអាជីវកម្ម និងធ្វើដំណើរកំសាន្ត នៅកម្ពុជា ដោយសប្បាយរីករាយ និងគ្មានការភ័យបារម្ភ។

តាមរបាយការណ៍ពីក្រុមការងារអនុវត្តច្បាប់ របស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួន ៩៩ ករណី ក្នុងនោះមានករណីអំពើជួញដូរមនុស្សបង្ក្រាបបាន ២៧ករណី ឃាត់ខ្លួនជនសង្ស័យ ៣៧នាក់(ស្រី ០៤នាក់)។ សង្គ្រោះជនរងគ្រោះ ៨១នាក់(ស្រី ២១នាក់) អនីតិជន ១៤នាក់(ស្រី០៤នាក់) និងករណីអំពើធ្វើអាជីវកម្មផ្លូវភេទបង្ក្រាបបាន ៧២ករណី ឃាត់ខ្លួនជនសង្ស័យ ៩៣នាក់(ស្រី ១៩នាក់) ជនបរទេស ០៧នាក់។ សង្គ្រោះជនរងគ្រោះ ១៩៧នាក់(ស្រី១៩២នាក់) អនីតិជន ១៤៦នាក់(ស្រី ១៤៥នាក់)។

ចំពោះចំណាត់ការផ្តន្ទាទោស ចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានី-ខេត្ត បានសម្រេចក្តី សរុបចំនួន ២៣៦សំណុំរឿង ក្នុងនោះ សំណុំរឿងចាស់ ១១៨ និងសំណុំរឿងថ្មី ១១៨ ដោយបានផ្តល់យុត្តិធម៌ជូនជនរងគ្រោះចំនួន ២៤៣នាក់(ស្រី២១១នាក់) អនីតិជន ១៥១នាក់(ស្រី១៤៦នាក់) និងជនបរទេស ១៦នាក់(ស្រី០៤នាក់)។ ជនជាប់ចោទចំនួន ៣៥៤នាក់(ស្រី ៤៧នាក់) អនីតិជន ៤០នាក់(ស្រី០២នាក់) និងជនបរទេស ៤៦នាក់ ដោយសម្រេចដាក់ឱ្យជាប់ពន្ធនាគារ ១០១នាក់(ស្រី ១០នាក់)។

ក្នុងកិច្ចការពារជនរងគ្រោះ ក្រុមការងារកិច្ចការពារជនរងគ្រោះ ដឹកនាំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានសហការជាមួយក្រសួង មន្ទីរ អង្គភាពពាក់ព័ន្ធ ជាពិសេស ក្រសួងការបរទេស នគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងកងរាជអាវុធហត្ថ ក្នុងការទទួលយកជនរងគ្រោះ និងអ្នកដែលសង្ស័យថាបានរងគ្រោះដោយអំពើជួញដូរមនុស្ស ទាំងនៅក្នុងប្រទេស និងពីប្រទេសពាក់ព័ន្ធ សរុបចំនួន ២០៣នាក់ (ស្រី ១៤២នាក់) អនីតិជន៤៨នាក់។ បន្ទាប់ពីបានកំណត់អត្តសញ្ញាណដោយមន្ត្រីនគរបាលយុត្តិធម៌រួចហើយ មានជនរងគ្រោះដោយអំពើជួញដូរមនុស្ស ១៩៤នាក់(ស្រី១៣៦នាក់) អនីតិជន៤៦នាក់ និងបានធ្វើសមាហរណកម្មជនរងគ្រោះ និងជនដែលសង្ស័យថារងគ្រោះ ឱ្យត្រឡប់ទៅសហគមន៍វិញដោយសុវត្ថិភាព ចំនួន៩២នាក់ (ស្រី៧៩នាក់) អនីតិជន ១១នាក់ ព្រមទាំងបានធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះជាបរទេសទៅប្រទេសដើមវិញ សរុបចំនួន ០៧នាក់ (ស្រី ០២នាក់) ជនជាតិ ឥណ្ឌា ០២នាក់ ស្រីលង្កា ០២នាក់ វៀតណាម ០២នាក់ និងជនជាតិចិន ០១នាក់។

អ្វីដែលជាការគួរឱ្យកត់សម្គាល់ ក្នុងឆ្នាំ២០២៥ នេះ គឺការកើតឡើងនូវទង្វើអមនុស្សធម៌ ទៅលើពលករកម្ពុជាដែលបាននិងកំពុងរស់នៅ និងធ្វើការយ៉ាងសកម្មនៅក្នុងប្រទេសថៃ ក្រោយពីមានបញ្ហាជម្លោះប្រដាប់អាវុធនៅព្រំដែន កម្ពុជា ថៃ និងឈានដល់សង្គ្រាមគម្រាមកំហែងសុវត្ថិភាពប្រជាពលរដ្ឋ បានធ្វើឱ្យប្រជាពលរដ្ឋនាំគ្នាភៀសខ្លួនមកនៅក្នុងជំរំភៀសសឹក ប្រមាណជិតម្ភៃម៉ឺននាក់។ ចំណែកពលករដែលបាននិងកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ បានទទួលរងនូវព្រមាន ការប្រមាថមាក់ងាយ ការរើសអើង កេងប្រវ័ញ្ច ការប្រើអំពើហិង្សា បណ្តេញចេញយ៉ាងអាណោចអធម ដែលធ្វើឱ្យពលករបង្ខំចិត្ត ត្រូវចាកចេញពីប្រទេសថៃ និងវិលត្រឡប់មកមាតុភូមិកម្ពុជាវិញយ៉ាងច្រើនកុះករតាមច្រកព្រំដែន។ ក្នុងស្ថានភាពដ៏លំបាកនេះ រាជរដ្ឋាភិបាលកម្ពុជា ចាំបាច់ត្រូវទទួលរ៉ាប់រងក្នុងការទទួលដោះស្រាយ ជីវភាព ការអប់រំស្តារនីតិសម្បទា កាត់បន្ថយវិបត្តិផ្លូវចិត្តរបស់ពលករ ព្រមទាំងបង្កើត និងបង្កើនការងារ មុខរបរ អាជីវកម្ម សេវាកម្ម ជូនប្រជាពលរដ្ឋ ជាពិសេស ពលករដែលវិលត្រឡប់ តាមកម្រិតនៃសេចក្តីត្រូវការ ឱ្យបានទាន់ពេលវេលា ដើម្បីបញ្ចៀសឱ្យបាន នូវភាពប្រថុយប្រថាន តាមការអូសទាញរបស់ជនល្មើស ដែលនាំឱ្យរងគ្រោះ ជាថ្មី ដោយអំពើជួញដូរ កេងប្រវ័ញ្ច និងរំលោភបំពាន ដោយអមនុស្សធម៌។

ជាចុងក្រោយ ក្នុងនាមអង្គពិធីទាំងមូល លោកជំទាវ សូមឱ្យការឧទ្ទិសបួងសួងក្នុងទិវាជាតិអន្តរសាសនានាពេលនេះ កើតបានជាកុសលផលបុណ្យជូនដល់វិញ្ញាណក្ខន្ធ វីរយុទ្ធជន វីរនគរបាល និងប្រជាពលរដ្ឋ ដែលបានបាត់បង់ជីវិតក្នុងសង្គ្រាមដ៏ជូរចត់កន្លងទៅនេះ សូមឱ្យបានទៅកាន់សុគតិភព និងទទួលបាននូវភាពស្ងប់សុខ ក្នុងជាតិកំណើតថ្មីក្នុងសុគតិភព និងសូមបន់ស្រន់ដល់ព្រះពុទ្ធ ព្រះអឡោះ ព្រះយេស៊ូ ជាម្ចាស់ ទេវតា និងវត្ថុស័ក្តិសិទ្ធិដ៏មានឫទ្ធិទាំងឡាយក្នុងលោក សូមប្រទានពរឱ្យពិភពលោក បានស្រស់ថ្លាឡើងវិញ គ្រប់ទីកន្លែង មនុស្សទាំងឡាយបានក្តីសុខ រួចផុតគ្រោះមហន្តរាយ និងទុក្ខភ័យទាំងឡាយ។ លោកជំទាវក៏សូមថ្វាយ និងប្រគេនពរ ដល់សម្តេចព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ **ឯកឧត្តមអភិសន្តិបណ្ឌិត និងលោកជំទាវ** មេដឹកនាំ និងសាសនិកគ្រប់សាសនានៅកម្ពុជា ឯកឧត្តម លោកជំទាវគណៈអធិបតី ឯកឧត្តម លោកជំទាវ លោក លោកស្រី យុវជន យុវនារី អង្គពិធីទាំងមូល សូមបានប្រកបដោយពុទ្ធពរ និងពរព្រះជាម្ចាស់ គ្រប់ប្រការ កុំបីឃ្លៀងឃ្លាតឡើយ។

## III. សេចក្តីថ្លែងការណ៍របស់តំណាងព្រះពុទ្ធសាសនា

សម្តេចព្រះពុទ្ធជ័យមុនីបណ្ឌិត **ឃឹម សន** សម្តេចព្រះសង្ឃនាយករងទី៣ និងជាមេគណរាជធានីភ្នំពេញបានយាងនិមន្តធ្វើសេចក្តីថ្លែងការណ៍អំពី តួនាទីព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ ក្នុងការចូលរួមបង្ការទប់ស្កាត់ និងកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

សម្តេចព្រះពុទ្ធជ័យមុនីបណ្ឌិត បានលើកឡើងថា ទិវាជាតិអន្តរសាសនានេះ នឹងនាំមកនូវជាប្រយោជន៍បានជ្រួតជ្រាបដល់ចិត្តគំនិតកូនខ្មែរទាំងអស់ ក្នុងការចូលរួមប្រយុទ្ធប្រឆាំងការជួញដូរមនុស្សទាំងក្នុងព្រះរាជាណាចក្រកម្ពុជា និងក្នុងពិភពលោកទាំងមូល។ ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ ប៉ុន្តែយើងក៏មានសាសនាដទៃទៀត

ដែលបាននិងកំពុងគោរពប្រណិប័តន៍ តាមជំនឿសាសនារៀងៗខ្លួនរបស់ប្រជាពលរដ្ឋ ដែលកំពុងយ៉ាងសុខសាន្តលើទឹកដីនៃព្រះរាជាចក្រកម្ពុជា ដែលនេះបង្ហាញពីសុខដុមនីយកម្មសាសនានៅកម្ពុជា ហើយគ្រប់និកាយសាសនាទាំងអស់មានតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមទប់ស្កាត់អំពើជួញដូរមនុស្សគ្រប់ទម្រង់ទាំងអស់ ពិសេស គឺ តម្លៃនៃគុណធម៌ព្រះពុទ្ធសាសនាបានអប់រំមនុស្សគ្រប់រូបឱ្យមានគុណធម៌តាមរយៈការរក្សាសីលប្រាំ មនុស្សមានគុណធម៌ គឺជាមនុស្សដែលប្រកបដោយមេត្តាចិត្ត ចេះស្រឡាញ់ ចេះអភ័យដល់សព្វសត្វទាំងអស់នៅក្នុងពិភពលោក។ វត្តអារាមជាទីកន្លែងកក់ក្តៅសម្រាប់សត្វលោកទាំងឡាយ ជាទីកន្លែងរក្សា បណ្តុះបណ្តាលចំណេះដឹង អក្សរសាស្ត្រ វប្បធម៌ អរិយធម៌ ប្រពៃណី ទំនៀមទម្លាប់។ល។ ពិសេស ថ្មីៗនេះទីវត្តអារាម បានទទួលនូវបងប្អូនជនភៀសសឹកជាច្រើន ដែលភៀសខ្លួនចេញពីផ្ទះសម្បែង ដោយសារមានការឈ្លានពាន់យ៉ាងគឃ្លើនពីសំណាក់កងទ័ពសៀម។

ព្រះពុទ្ធសាសនា អប់រំមនុស្សឱ្យមានភាពរឹងមាំ ទាំងផ្លូវកាយ និងផ្លូវចិត្ត ឱ្យមានខ្លួនឯងទីពឹងដ៏កក់ក្តៅបំផុត ប្រកបដោយបញ្ញាញាណ គុណធម៌ សុជីវធម៌ សីលធម៌ ចរិយាធម៌ និងមានអាជីពត្រឹមត្រូវដើម្បីចិញ្ចឹមជីវិត ដែលប្រកបដោយបញ្ញា។ ព្រះពុទ្ធសាសនា បានហាមឃាត់ប្រកបរបរបួនប្រការ ក្នុងនោះក៏មានការជួញដូរមនុស្សនេះដែរ ព្រោះការជួញដូរមនុស្សជាទោសធ្ងន់ដែលត្រូវធ្លាក់ក្នុងអបាយភូមិ។

ក្រោយពីបានបញ្ចប់ សេចក្តីថ្លែងការណ៍របស់ តំណាងព្រះពុទ្ធសាសនា រួចមក ក៏មានកិច្ចសូត្រព្រះធម៌ ដើម្បីបួងសួង អធិដ្ឋានសុំសេចក្តីសុខ តាមសាសនានីមួយៗ ជាបន្តបន្ទាប់។

## III. **សុន្ទរកថា និងប្រសាសន៍សំណេះសំណាល**

ក្នុងឱកាសដ៏ថ្លៃថ្លានេះ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានសម្តែងនូវក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដែលបានចូលរួមក្នុងទិវាជាតិអន្តរសាសនា លើកទី៩ ដែលរៀបចំ ដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមប្រធានបទ «សុខដុមនីយកម្មសាសនានៅកម្ពុជា ជាសក្តានុពលក្នុងការប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ នាសម័យបច្ចេកវិទ្យា» នេះគឺជាបង្ហាញនូវការជួបជុំដ៏មានអត្ថន័យដែលបង្ហាញពីការសាមគ្គីភាព ឯកភាព និងសុខដុមនីយកម្មនៃគ្រប់ជំនឿសាសនាក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជាមូលដ្ឋានគ្រឹះនៃសន្តិភាព ធ្វើឱ្យមនុស្សមានសេចក្តីសុខ ទាំងផ្លូវកាយ និងផ្លូវចិត្ត ចាកទុក្ខភ័យទាំងឡាយដែលបង្កដោយមនុស្ស ឬដោយធម្មជាតិក្តី។

ឯកឧត្តមអភិសន្តិបណ្ឌិត មានប្រសាសន៍បន្តថា ចាប់តាំងពីឆ្នាំ២០១៧ មក កម្ពុជា តែងប្រារព្ធកម្មវិធីអន្តរសាសនាប្រឆាំងអំពើជួញដូរមនុស្សយ៉ាងអធិកអធម ក្រោមការគាំទ្រប្រកបដោយឆន្ទៈមោះមុត របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាប្រធានព្រឹទ្ធសភា អតីតនាយករដ្ឋមន្ត្រី និងសម្តេចក្រឡាហោម **ស ខេង** ឧត្តមក្រុមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ អតីតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ នៅក្នុងឆ្នាំ២០២១ ក្នុងនីតិកាលទី៦ នៃរដ្ឋសភា អំឡុងពេលរីករាលដាលនៃជំងឺកូវីដ-១៩ បើទោះជាគ្មានការជួបជុំគ្នាជាទ្រង់ទ្រាយធំក្តី **សម្តេច តេជោ** បានធ្វើសេចក្តីថ្លែងសារជាសម្លេង និងវីដេអូ ដើម្បីអបអរទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស ដោយមានការទូងស្គរនៅតាមបណ្តាវត្តអារាមនានាទូទាំងប្រទេស ដើម្បីរំលឹកពីសារសំខាន់ និងការចូលរួមក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ឆ្នាំ២០២២ **សម្តេច ហ៊ុន សែន** បានកំណត់យកថ្ងៃទី ២០ សីហា រៀងរាល់ឆ្នាំ ជាថ្ងៃប្រារព្ធ ទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរការមនុស្ស។ ក្នុងនីតិកាលទី៧ នៃរដ្ឋសភា ទិវាជាតិអន្តរសាសនាបានប្រារព្ធធ្វើឡើងតាមរយៈមិទ្ទិញថ្នាក់ជាតិ ដោយមានការយាងនិមន្ត និងចូលរួមយ៉ាច្រើមកុះករ ពីតំណាង ព្រះពុទ្ធសាសនា ឥស្លាមសាសនា គ្រីស្ទសាសនា សមាជិករាជរដ្ឋាភិបាល មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ

វិស័យឯកជន សិស្ស និស្សិត និងប្រជាពលរដ្ឋ ដែលបង្ហាញពីការសាមគ្គីជាធ្លុងមួយក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

រាជរដ្ឋាភិបាលនីតិកាលទី៧ ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្រ្តី** បាននិងកំពុងបន្តដឹកនាំប្រទេសជាតិយ៉ាងស្វាហាប់ ឆ្ពោះទៅកាន់ចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ តាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងបន្តប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងប្រយុទ្ធប្រឆាំងដាច់ខាតអំពើជួញដូរមនុស្សគ្រប់ទម្រង់ និងបទល្មើសឧក្រិដ្ឋដទៃទៀត ដែលជាឧបសគ្គរាំងដល់ដំណើរការនៃការអភិវឌ្ឍប្រទេសជាតិ។ សុខដុមនីយកម្មសាសនានៅកម្ពុជា បង្ហាញនូវការសាមគ្គីគ្នា ការយោគយល់គ្នា និងការរួមគ្នាក្នុងការដោះស្រាយបញ្ហាទាំងឡាយនៅក្នុងសង្គម រួមទាំងអំពើជួញដូរមនុស្ស តាមរយៈការបង្ការទប់ស្កាត់ដោយការអប់រំតាមបែបសីលធម៌។

ជាទីបញ្ចប់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានថ្លែងអំណរគុណដល់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលបានរៀបចំ ទិវាជាតិអន្តរសាសនា នេះឡើងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដែលឆ្លុះបញ្ចាំងពីសុខដុមនីយកម្មសាសនានៅកម្ពុជា ការសាមគ្គីភាព និងសុខសន្តិភាពទាំងផ្លូវកាយ និងផ្លូវចិត្ត។ **ឯកឧត្តមអភិសន្តិបណ្ឌិត** ក៏បានថ្លែងអំណរព្រះគុណ និងប្រគេនពរ សម្តេចសង្ឃទាំងពីរគណៈ និងជូនពរមេដឹកនាំសាសនាទាំងអស់ ឯកឧត្តម លោកជំទាវ មន្ត្រីរាជការ សិស្ស និស្សិត និងបងប្អូនប្រជាពលរដ្ឋដែលបានចូលរួមក្នុងកម្មវិធីនាពេលនេះ សូមប្រកបតែសេចក្តីសុខ សន្តិភាព និងជួបប្រទះពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ទិវាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស ២០ សីហា ឆ្នាំ២០២៥ ក្រោមប្រធានបទ «**សុខដុមនីយកម្មសាសនានៅកម្ពុជា ជាសក្តានុពលក្នុងការប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ នាសម័យបច្ចេកវិទ្យា**» បានបញ្ចប់នៅវេលាម៉ោង ដប់ប្រាំពីរនិងសូន្យនាទីល្ងាច ថ្ងៃ ខែ ឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ និងអធិកអធមក្រៃលែង។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **លោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

ថ្ងៃ.ច័ន្ទ...២.កើត.ខែ.ភទ្របទ..ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ, ថ្ងៃទី..២៥..ខែ..សីហា..ឆ្នាំ២០២៥
**អ្នកធ្វើរបាយការណ៍**

វរសេនីយ៍ឯក.អ៊ិច ចាន់ធា

បានពិនិត្យ និងគោរពជូន
លោកជំទាវ អគ្គលេខាធិការ មេត្តាជ្រាបជារបាយការណ៍។
រាជធានីភ្នំពេញ, ថ្ងៃទី...២៥....ខែ...សីហា.....ឆ្នាំ២០២៥
**អគ្គលេខាធិការរង**

ឧត្តមសេនីយ៍ឯក.យ៉ែម_ចំនួណារុំ

បានពិនិត្យ និងគោរពជូន
លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។
រាជធានីភ្នំពេញ, ថ្ងៃទី..២៦...ខែ....សីហា...ឆ្នាំ២០២៤
**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯករង្ស.ប៊ុណ្ណា សំខាន់

26/08/25
ជុំ_ប៊ុនអេង